ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៦៥...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់

## សម្រេច

**មាត្រា ១.-**

បង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៅមន្ទីរពេទ្យបង្អែកខេត្តចំនួន០៤ នៃក្រសួងសុខាភិបាល ដែលមានដូចខាងក្រោម ÷

១. មន្ទីរពេទ្យបង្អែកខេត្តកំពត

២. មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង

៣. មន្ទីរពេទ្យបង្អែកខេត្តក្រចេះ

៤. មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ។

**មាត្រា ២.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល ដូចមានចែងក្នុងមាត្រា១ គឺជាទីភ្នាក់ងារមួយរបស់ក្រសួងសុខាភិបាល ដែលមានមុខងារពិសេសក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ហើយស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសុខាភិបាល និងមានភារកិច្ចចម្បងៗដូចខាងក្រោម ÷

- ផ្តល់សេវាសុខភាពសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា
- លើកកម្ពស់ការគ្រប់គ្រងផ្តែកលើលទ្ធផលការងារ
- សំដៅកែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រីរាជការ ស្របតាមលក្ខណសម្បត្តិរបស់រដ្ឋបាលសាធារណៈ
- អភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ។

**មាត្រា ៣.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលជាមន្ទីរពេទ្យបង្អែកខេត្តដូចមានក្នុងមាត្រា១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ។

**មាត្រា ៤.-**

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌបេសកកម្ម និងក្នុងកិច្ចសន្យាគ្រប់គ្រង។

លក្ខខណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រងគំរូជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ ត្រូវទទួលខុសត្រូវក្នុងដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានមន្ទីរសុខាភិបាលខេត្តដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ។

**មាត្រា ៦.-**

មន្ត្រីដែលបម្រើការងារក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមមន្ទីរពេទ្យបង្អែកខេត្ត ដូចបានកំណត់ក្នុងមាត្រា១ ជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងសុខាភិបាល។

មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងនេះ ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ តាមរយៈអ្នកគ្រប់គ្រងមន្ត្រីផ្ទាល់។

**មាត្រា ៧.-**

មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល ត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តដែលបានមកពីការបែងចែកប្រាក់សេវា ហិរញ្ញប្បទានប្រាក់ធានារ៉ាប់រងសង្គម ប្រាក់មូលនិធិសមធម៌ និងប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស។

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តខាងលើនេះ ត្រូវអនុវត្តតាមការណែនាំជាក់ស្តែងរបស់ក្រសួងសុខាភិបាល។ បន្ថែមពីលើនេះ ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗអាចផ្តល់ជូនប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទៅតាមលទ្ធផលការងារ និងស្ថានភាពជាក់ស្តែង នៃទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ។

**មាត្រា ៨.-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវធ្វើឡើងនៅតាមអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ តាមប្រព័ន្ធធនាគារ។

**មាត្រា ៩.-**

ប្រភពធនធាន និងចំណូលថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល បានមកពី ÷

- ថវិកាជាតិ
- ប្រាក់សេវាហិរញ្ញប្បទាន
- ប្រាក់ធានារ៉ាប់រងសង្គម
- ប្រាក់មូលនិធិសមធម៌ និង
- ប្រភពផ្សេងៗទៀតប្រសិនបើមាន។

**មាត្រា ១០.-**

ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធានាផ្តល់ថវិកាឱ្យបានទាន់ពេលវេលាដល់ទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗសម្រាប់ប្រតិបត្តិការការងារ។

**មាត្រា ១១.-**

ក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវលើការបង្កើតឱ្យមានយន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ ហើយបញ្ជូនរបាយការណ៍លទ្ធផលនៃការបំពេញការងារប្រចាំឆ្នាំទៅគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ